នឹកដល់គ្រាមួយនោះ ...

*ខ្ញុំបានស្គាល់បុរសម្នាក់ដែលត្រូវជាមិត្តរបស់បងប្រុសមិត្តខ្ញុំ ... កាលនោះ ខ្ញុំមានអាយុ១៦ឆ្នាំនិង ៣ខែ ... គឺខ្ញុំទើបតែចូលរៀនក្នុងថ្នាក់ទី៧កាលពីបួនខែមុននេះឯង។ រំឭកដល់អតីតកាលនៃកំឡុងឆ្នាំ១៩៨០ ការប្រលងនៅចុងថ្នាក់ទី៧ មានការលំបាកតឹងតែងនោះក្រៃណាហៅលំបាក។ គឺពួកយើងត្រូវប្រលងពីរដង ... ការប្រលងលើកទីមួយត្រូវធ្វើឡើងនៅខែមិថុនា សម្រាប់បញ្ចប់មធ្យមសិក្សាបឋមភូមិ (ដែលកាលនោះគេហៅឈ្មោះថាមធ្យមសិក្សាកំរិត១) យើងហៅការប្រលងនេះថា **ប្រលងយកសញ្ញាប័ត្រ** ... ការប្រលងលើកទីពីរត្រូវធ្វើឡើងនៅខែសីហា សម្រាប់ចូលរៀននៅសាលាពេលថ្ងៃដើម្បីបន្តការសិក្សារបស់ពួកយើងទៅមធ្យមសិក្សាទុតិយភូមិ (កាលនោះត្រូវគេឱ្យឈ្មោះថាមធ្យមសិក្សាកំរិត២) យើងហៅការប្រលងនេះថា **ប្រលងយកកៅអី** ... ដ្បិតអីកាលនោះកន្លែងសម្រាប់ឱ្យសិស្សសិក្សាពេលថ្ងៃមានកំណត់ គឺក្នុងចំណោមសិស្សដែលប្រលងបានសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ អាចមានតែមួយភាគបីប៉ុណ្ណោះត្រូវគេជ្រើសរើសឱ្យចូលរៀនបន្តនៅសាលាចំណេះទូទៅពេលថ្ងៃ ... អ្នកដែលបរាជ័យក្នុងការប្រលងកៅអី ត្រូវគេណែនាំឱ្យជ្រើសរើសរៀនមុខវិជ្ជាឯកទេសថ្នាក់មធ្យម ឬត្រូវចូលបម្រើកងទ័ព ... អ្នកទាំងនេះអាចបន្តការសិក្សាទៅមធ្យមសិក្សាកំរិត២បានដែរ តែត្រូវរៀននៅពេលយប់ ... តើនេះបណ្តាលមកពីស្រុកយើងក្រ ខ្វះថ្នាក់រៀន ខ្វះគ្រូ ហើយសម្បូរអ្នកចូលចិត្តតស៊ូចង់បន្តការសិក្សាកំរិតខ្ពស់ឬអ្វី? ហេតុផលពិតប្រាកដយ៉ាងណាខ្ញុំមិនដឹងទេ តែការប្រលងយកកៅអី គឺជាការប្រលងប្រជែងយ៉ាងលំបាកបំផុតការក្នុងរយៈកាលសិក្សានៅចំណេះទូទៅរបស់យើង ... ឯមុខវិជ្ជាត្រូវចេញជាវិញ្ញាសារប្រលងមានតែពីរប៉ុណ្ណោះ គឺ**អក្សរសាស្ត្រខ្មែរ** និង **គណិតវិទ្យា**។*

ដើម្បីត្រៀមយកជោគជ័យក្នុងការប្រលងកៅអី ខ្ញុំនិងមិត្តភក្តិមួយចំនួនបានបង្កើតជាក្លឹបសិក្សាគណិតវិទ្យានៅផ្ទះរបស់មិត្តខ្ញុំម្នាក់។ គាត់ក៏ត្រូវបានអញ្ជើញឱ្យមកធ្វើជាអ្នកដឹកនាំក្លឹប ដើម្បីជួយពន្យល់ណែនាំពួកយើងក្នុងការធ្វើលំហាត់ ព្រោះគាត់ល្បីពីរឿងពូកែម៉ាត់(គណិតវិទ្យា)។ ពេលឃើញមុខគាត់ដំបូងខ្ញុំពុំសូវជាចូលចិត្តគាត់ប៉ុន្មានទេ ព្រោះខ្ញុំគិតថាគាត់កាច់រាងធ្វើជាមនុស្សចាស់ទុំនិងខំសម្តែងឫកជាមនុស្សមឺងម៉ាត់ជ្រុល ... រហូតដល់អត់ចេះញញឹម ... មិត្តខ្ញុំភាគច្រើនខ្លាចគាត់រហូតដល់បាត់មាត់ ពេលឆ្លៀតអីក៏អត់ហ៊ានសួរ ... ពួកយើងចាត់ទុកគាត់ដូចជាលោកគ្រូ ... ឯគាត់ក៏ទំនងជាចាត់ទុកពួកយើងដូចជាកូនសិស្សដែរ ... ប៉ុន្តែរយៈពេលពីរ-បីខែកន្លងផុតទៅ គាត់ក៏ចាប់ផ្តើមចេះរួសរាយ ចេះនិយាយលេងពីនេះពីនោះខ្លះជាមួយពួកយើង នៅពេលសម្រាកពីធ្វើលំហាត់ឬពេលបញ្ចប់ម៉ោងសិក្សា។ មិនយូរប៉ុន្មានគាត់ក៏ចាប់ផ្តើមចេះលើកបញ្ហាក្នុងអក្សរសិល្ប៍មកជជែកវែកញែកជាមួយខ្ញុំ ... ជួនកាលខ្ញុំនិងគាត់បានទាំងប្រកែកគ្នាទៀតផង ព្រោះតែការយល់ឃើញខុសគ្នា។

ស្រាប់តែថ្ងៃមួយ មិត្តខ្ញុំម្នាក់បានប្រាប់ខ្ញុំថា គាត់បានជំរិតវាសួរចម្ងើយពីរឿងខ្ញុំច្រើនណាស់ ... ខ្ញុំមានផារជាស្រីចរិតប្រុសតែឆ្នាស ... បើដូចពេលមុនៗ ខ្ញុំមុខតែតាមរករឿងគាត់ ថាកុំឱ្យមកចេះចង់គាស់កកាយរឿងរបស់ខ្ញុំពីក្រោយខ្នង បើមានបំណងចង់ដឹងអ្វីពីខ្ញុំ សុំឱ្យចេញមុខមកសួរដោយត្រង់ៗ! ... តែលើកនេះខ្ញុំបែរជាស្ងួត ខ្ញុំមិនមាត់អ្វីទេ គ្រាន់តែលួចញញឹម ... គួរឱ្យចម្ងៃកដែរ ហេតុអីមនុស្សទឹសមឹសឫកធំនេះចេះមកចាប់អារម្មណ៍នឹងខ្ញុំ ... ប្រហែលជាខ្ញុំមានលក្ខណៈពិសេសអ្វីម្យ៉ាងហើយហ្ន៎? និយាយលាក់បាំងអីមួយរយៈកន្ទងមកនេះខ្ញុំក៏ចាប់ផ្តើមមានអារម្មណ៍ល្អនឹងគាត់ជាបណ្តើរៗហើយដែរ ... ខ្ញុំចាប់ផ្តើមចូលចិត្តនិងគោរពភាពនឹងនរជាចាស់ទុំ ភាពមុឺងម៉ាត់ និងភាពធ្ងៀវធ្ងាតរបស់គាត់ជាលំដាប់ ... រូបសម្បត្តិគាត់ក៏សមសួនសង្ហា មើលទៅមិនទាស់នេត្រាត្រង់ណាទេ ... ខ្ញុំជាមនុស្សទាមទារខ្ពស់អញ្ចឹងណ៎ា ... គ្រាន់តែមានប្រាជ្ញាមិនទាន់គ្រប់គ្រាន់ទេ ត្រូវឱ្យមានភាពសង្ហាទាក់ភ្នែកខ្លះផងដែរ ទើបបានទៅរួច ...។

*ខ្ញុំមិនទាន់ទាំងបានគិតត្រៀមខ្លួនអ្វីបន្តិចផង ក៏ធ្លាក់ក្នុងអន្ទង់ស្នេហ៍គាត់ទៅហើយ ... ខ្ញុំមិនដែលមានអារម្មណ៍បែបនេះពីមុនមកឡើយ ... តាំងតែពីដើមរៀងមក ខ្ញុំចូលចំណោមនឹងក្មេងស្រីមិនសូវចុះទេច្រើនតែទៅចូលចំណោមនិងលេងជាមួយក្មេងប្រុសៗ (មានអ្នកខ្លះរហូតដល់ទៅហៅខ្ញុំដោយចំអន់ថា **អាប្រុសៗ**ផង) ព្រោះខ្ញុំអត់ចូលចិត្តលេងកូនក្រមុំឬលេងបាយឡុកបាយឡ ខ្ញុំអត់ចេះស្ងៀកសារ៉ុងកៅស៊ូលេងលោតមឹកឬលោតអន្ទាក់ជាមួយក្មេងស្រីសោះ ខ្ញុំចូលចិត្តតែស្ងៀកខោខ្លីលេងរត់ដេញបាញ់គ្នាឬឡើងដើមឈើជាមួយពួកក្មេងប្រុសៗ។ បើមានការវាយតប់គ្នាវិញ ខ្ញុំមិននិយមពីរឿងបោចសក់ឬក្រញ៉ៅមុខគ្នាតាមបែបក្មេងស្រីគេឈ្លោះគ្នាឡើយ ខ្ញុំចូលចិត្តប្រើក្បាច់ជាល់ឬទាត់យ៉ាងពិតប្រាកដ! ខ្ញុំខិតខំហ្វឹកហាត់ក្បាច់គុនតាមលំនាំរឿងបុរាណចិនដែលខ្ញុំចូលចិត្តអាន គឺខ្ញុំខំយួរធុងទឹកវាល់ថ្ងៃដើម្បីឱ្យឡើងសាច់ដុំដៃ ខ្ញុំខំដាល់បាវខ្សាច់ឬដាល់ជញ្ជាំងសឹងបាក់ម្រាមដៃអស់ហើយ ខ្ញុំខំរៀនក្បាច់ជង្គង់ហោះកែងហើរទៀតផង! បើខ្ញុំវាយដោយដៃជើងមិនឈ្នះគេទេ ខ្ញុំនៅសល់ក្បាច់ពិសេសមួយទៀត គឺក្បាច់ខាំ ... ក្មេងប្រុសដទៃគេមិនសូវចេះប្រើក្បាច់ខាំទេ នេះជាក្បាច់ពិសេសរបស់ខ្ញុំ បើមិនចាំបាច់ខ្ញុំក៏មិនប្រើដែរ ... តែបើប្រើហើយតោងតែមានជ័យជំនះ! ដូច្នេះហើយតាំងពីតូចដល់ធំ មិត្តភក្តិជិតស្និទ្ធដែលយល់ចិត្តខ្ញុំ ច្រើនតែជាប្រុសៗ! ខ្ញុំក៏មានមិត្តជិតស្និទ្ធជាស្រីដែរ តែពួកនោះច្រើនតែជាជំពូកពុម្ពតែមួយនឹងខ្ញុំនេះឯង ... អញ្ចឹងហើយទើបអារម្មណ៍មានស្នេហាដំបូងរបស់ខ្ញុំចំពោះបុរសម្នាក់នោះ វាជាអារម្មណ៍ដ៏ថ្មីស្រឡាងនិងចម្ងៃកក្រៃពេក!*

*ពួកយើងមិនត្រឹមតែជួបគ្នាមួយអាទិត្យបីដងនៅឯក្លឹបគណិតវិទ្យាទេ គាត់បានមកចាំខ្ញុំនៅវាល់ពេលខ្ញុំចេញពីសាលា ហើយជិះកង់ទន្ទឹមខ្ញុំ ជូនខ្ញុំទៅដល់ផ្ទះវាល់ថ្ងៃ ... ពួកយើងមានរឿងជជែកគ្នាល្អកល្អិនជាហូរហែរចប់តែផ្លូវ ... ប៉ុន្តែខ្ញុំមិនដែលអញ្ជើញគាត់ឱ្យចូលលេងក្នុងផ្ទះទេ ព្រោះខ្ញុំខ្មាស ... ខ្ញុំមិនដែលប្រកាសប្រាប់នរណាថាគាត់ជាសង្សារខ្ញុំឡើយ ... ព្រោះសម័យនោះ គេមានជំនឿថា **ស្នេហាគឺជាសត្រូវនឹងការសិក្សា** ... សិស្សណាដែលមានស្នេហាហើយនឹងត្រូវវង្វេងបែកធ្វេង លែងគិតគូរពីការរៀនសូត្រ*

អនាគតនឹងត្រូវរលត់រលាយទៅតាមនោះ! បើបែបហ្នឹងតើឱ្យខ្ញុំចេញមុខប្រាប់អ្នកក្នុងផ្ទះឱ្យដឹងថាខ្ញុំទទួលគាត់ធ្វើជាសង្សារម្តេចនឹងបាន? ខ្ញុំចេះតែគិតថាតើខ្លួនខ្ញុំអាចខិលខូចដូចនាងទាវទេ? ចម្ងើយគឺទេ! ព្រោះខ្ញុំដឹងថាខ្ញុំកំពុងធ្វើអ្វី គ្រាន់តែពួកយើងស្រលាញ់គ្នាចិត្តនឹងចិត្ត ខ្ញុំគិតថាវាមិនខូចខាតអ្វីឡើយ! កាលនោះខ្ញុំខំរៀនខ្លាំងណាស់ ព្រោះទីមួយដើម្បីប្រឆាំងនឹងជំនឿថាស្នេហាគឺជាសត្រូវនឹងការសិក្សា ឯទីពីរគឺមកពីខ្ញុំស្រលាញ់បុរសម្នាក់នេះដែលល្បីថាជាមនុស្សរៀនពូកែហើយឆ្លាត បើខ្ញុំមិនខំរៀនឱ្យពូកែ មិនឆ្លាតវាងវៃទេ ធ្វើម៉េចខ្ញុំសក្តិសមនឹងគាត់? ដោយសារការខំប្រឹងប្រែងនេះ ខ្ញុំបានទទួលពិន្ទុខ្ពស់ៗស្ទើរតែគ្រប់មុខវិជ្ជា ... នោះគឺជាវេលាដែលខ្ញុំមានក្តីសុខនិងរីករាយបំផុត ... ខ្លួនខ្ញុំដូចជាអណ្តែតនៅលើអាកាស ... តើមាននរណាខ្លះមានអារម្មណ៍ទាំងបីនេះក្នុងពេលតែមួយ ... អារម្មណ៍ជោគជ័យ ... អារម្មណ៍នៃក្តីស្រលាញ់ដែលយើងមានឱ្យគេ ... អារម្មណ៍នៃក្តីស្រលាញ់ដែលគេផ្តល់ឱ្យយើង? ថ្ងៃបើយ៉ាងនេះក្តី ខ្ញុំនៅតែលាក់គាត់ទុកត្រឹមជាសង្សារសម្ងាត់ មិនដែលហ៊ានចេញមុខចេញមាត់ទៅណាជាមួយគ្នា មិនដែលហ៊ានប៉ះដៃប៉ះជើងគ្នាទេ ក្រៅតែពីការជិះកង់បណ្តើរគ្នាមកផ្ទះ ... ព្រោះថាការហ៊ានមានសង្សារក្នុងវ័យសិក្សាវាយ៉ាប់ណាស់ទៅហើយ ... ម្យ៉ាងទៀតខ្ញុំជាកូនស្រីមានពូជពង្សវង្សត្រកូល ការទៅទាក់ទងរើសសង្សារឬរើសស្វាមីដោយចិត្តឯង គឺជារឿងពុំប្រពៃ ... គេថាកូនស្រីយកប្តីចិត្តឯងនឹងគ្មានលទ្ធផលល្អទេ ... បើថ្ងៃក្រោយមិនត្រូវមេម៉ាយយ៉ាងអាម៉ាស ក៏មុខតែរងគ្រោះព្រោះបានប្តីមិនល្អ ... ខ្ញុំបានតាំងចិត្តប្តេជ្ញាថាមិនឱ្យមានរឿងបែបនោះកើតឡើងឡើយ! ខ្ញុំជឿជាក់ថាគាត់ជាមនុស្សល្អ ខ្ញុំចង់បញ្ជាក់ថាខ្ញុំរើសមនុស្សមិនខុស ... ប៉ុន្តែខ្ញុំទុកឱ្យពេលវេលាជាអ្នកបង្ហាញចុះថាខុសឬមួយត្រូវ! ខ្ញុំមានទំនុកចិត្តលើសេចក្តីស្នេហាដោយគ្មានក្តីសង្ស័យរដល់តិចតួចសោះ ... ខ្ញុំគិតថាក្តីស្នេហារបស់ខ្ញុំជាចំណងស្នេហ៍បរិសុទ្ធឥតមន្ទិល មិនថាពេលយូរកន្លងទៅប៉ុណ្ណាទេ ពួកយើងនឹងនៅតែស្រលាញ់គ្នានិងល្អនឹងគ្នាបែបនេះរហូតទៅ!

ខ្ញុំបានប្រាប់គាត់ថាមុននឹងខ្ញុំរៀបការ ខ្ញុំត្រូវតែយកឱ្យបានយ៉ាងហោចណាស់ក៏សញ្ញាប័ត្រឧត្តមសិក្សាមួយសិនដែរ! គាត់សម្តែងនូវក្តីអបអរសាទរគាំទ្រគំនិតរបស់ខ្ញុំ ហើយថាគាត់នឹងជួយជ្រោមជ្រែងឱ្យខ្ញុំបានសម្រេចនូវប្រាថ្នានេះ! គាត់ថាកុំឱ្យខ្ញុំព្រួយ គាត់ប្រកាសថារូបខ្ញុំគឺជាស្នេហ៍ទីមួយនិងជាស្នេហ៍តែមួយរបស់គាត់! គាត់បានទាំងស្បថថា ក្រៅពីរូបខ្ញុំគាត់មិនស្រលាញ់ មិនរៀបការជាមួយស្រីណាឡើយ!

ខ្ញុំបានប្រលងជាប់ ចូលរៀននៅថ្នាក់ទី៨ដោយក្តីមោទនៈ ... ក្លឹបសិក្សាគណិតវិទ្យាក៏ត្រូវបានរំសាយ ... សមាជិកក្លឹបភាគច្រើនមិនបានប្រលងជាប់ចូលរៀនពេលថ្ងៃទេ ... ពួកយើងក៏បែកខ្ញែកគ្នាអស់ទៅ។ គាត់នៅតែមកចាំខ្ញុំនៅសាលារាល់ពេលចេញទៅផ្ទះ ... គាត់តែងអង្គុយលើកង់ក្រោមដើមស្វាយដែលស្ថិតនៅក្នុងបរិវេណសាលាតែនៅមិនឆ្ងាយប៉ុន្មានពីក្បែរទ្វារមុខសាលាទេ ... ខ្ញុំអាចមើលឃើញគាត់ពីលើអាគារសិក្សារបស់ខ្ញុំដោយស្រួល។ ឯរូបខ្ញុំតែងមានរវល់នឹងកិច្ចការសាលាក្រោយម៉ោងសិក្សាជារឿយៗ ព្រោះពួកយើងត្រូវធ្វើគម្រោងផ្សេងៗ ត្រូវប្រជុំពិភាក្សាគ្នា ... គួរឱ្យអាណិតគាត់ណាស់ ព្រោះជួនកាលគាត់ត្រូវអង្គុយសំកុកចាំខ្ញុំយ៉ាងកណ្តោចកណ្តែងដល់ទៅ៤៥នាទី ... ប៉ុន្តែខ្ញុំមិនដឹងជាធ្វើយ៉ាងណាទេ ព្រោះខ្ញុំ

ជាសមាជិកសកម្មក្នុងក្រុមស្ម័យសិក្សា ... ចិត្តខ្ញុំត្រូវទទួលទំនាញទាំងសងខាង ... ខ្ញុំក៏មិនស្រួលអ្វីប៉ុន្មានដែរ! លុះមកដល់ចុងឆ្នាំសិក្សានៃថ្នាក់ទី៨ គាត់ចាប់ផ្តើមអស់ក្តីអត់ធ្មត់ និងចាប់ផ្តើមរអ៊ូរទាំថាខ្ញុំអត់ស្រលាញ់គាត់ អត់ខ្វល់ពីគាត់ ដូចដែលគាត់ស្រលាញ់ខ្ញុំនិងខ្វល់ពីខ្ញុំទេ! ខ្ញុំប្រាប់គាត់ថាការយល់ឃើញរបស់គាត់វាមិនពិត! តាមអីគាត់ជានិស្សិតឧត្តមសិក្សា (នៅសាលាសេដ្ឋកិច្ច) គាត់មានពេលទំនេរច្រើនឯខ្ញុំដូចឃើញស្រាប់ គឺរវល់មិនសូវចេះទំនេរ ព្រោះខ្លាចរៀនមិនឈ្នះគេ។ ក្រោយមកទៀតគាត់ចាប់ផ្តើមបង្ហាញសញ្ញានៃការប្រច័ណ្ឌ ចេះតែនិយាយថាអ្នកនេះអ្នកនោះស្រលាញ់ខ្ញុំ! ខ្ញុំខឹងផងខ្លាញ់ផង ព្រោះគាត់ដូចជាមិនយល់ចិត្តខ្ញុំសោះ ខ្ញុំក៏តបទៅគាត់ថា "រួចបងចង់ឱ្យខ្ញុំធ្វើយ៉ាងណា? តើខ្ញុំអាចនិយាយហាមគេគ្រប់គ្នាមិនឱ្យស្រលាញ់ខ្ញុំបានដែរឬ? ឬបងចង់ឱ្យខ្ញុំពាក់ផ្ទាកដើរប្រកាសប្រាប់គេថា ***អ្នកទាំងឡាយអើយកុំស្រលាញ់ខ្ញុំ ព្រោះខ្ញុំមានសង្សារហើយ!*** *អ្នកណាក៏អាចស្រលាញ់ខ្ញុំបានដែរ! រឿងសំខាន់គឺខ្ញុំមិនស្រលាញ់គេ មិនបានទៅដើរទាក់ទាញគេឱ្យមកស្រលាញ់ខ្ញុំទេ! ឬប៉ុណ្ណឹងហើយបងនៅយល់ថាមិនគ្រប់គ្រាន់ទៀត? ខ្ញុំមិនដែលគិតសង្ស័យដល់ភក្តីភាពរបស់បងចំពោះខ្ញុំទេ ព្រោះខ្ញុំជឿជាក់លើបង! តែហេតុអីបងមិនជឿជាក់លើខ្ញុំ?"*

គាត់ប្រកែកថាគាត់ជឿជាក់លើខ្ញុំ តែគាត់មិនទុកចិត្តពួកមិត្តប្រុសៗរបស់ខ្ញុំទាំងនោះទេ! ខ្ញុំចង់វង្វេងហើយព្រោះខ្ញុំមិនដែលនឹកគិតថានឹងបានសង្សារចេះប្រច័ណ្ឌបែបហ្នឹងសោះ! ... ខ្ញុំគិតថាការប្រច័ណ្ឌគឺការមិនទុកចិត្តគ្នាមិនឱ្យតម្លៃដល់មនុស្សដែលយើងស្រលាញ់ ... ខ្ញុំចាប់ផ្តើមគិតថាគាត់ប្រហែលមិនឱ្យតម្លៃខ្ញុំនិងគោរពចិត្តខ្ញុំ ដូចដែលខ្ញុំស្រលាញ់និងគោរពគាត់ទេ ... វាគួរឱ្យតូចចិត្តណាស់! ខ្ញុំក៏បញ្ជាក់ប្រាប់គាត់ថាខ្ញុំស្រលាញ់គាត់ណាស់ តែមិនមែនបានសេចក្តីថាខ្ញុំចាំតែផ្គាប់ផ្គុនចិត្តគាត់ម្នាក់ ហើយផ្តាច់ខ្លួនចេញពីការសិក្សានិងឈប់រាប់រកមិត្តភក្តិប្រុសៗដែលគេតែងតែល្អនឹងខ្ញុំរហូតមកនោះទេ! ខ្ញុំបានឱ្យយោបល់ថាគាត់ប្រហែលជាកើតក្តីធុញថប់ព្រោះតែមកត្រូវចាំខ្ញុំរាល់ថ្ងៃ ... ដូច្នេះគាត់គួរតែសម្រាកខ្លះទៅ ពួកយើងគួរតែកុំសូវជួបគ្នាញឹកញាប់បែបនេះពេក ទើបវាមិនសូវធុញទ្រាន់នឹងគ្នា! គាត់មានមុខមិនរីក តែក៏ធ្វើតាមពាក្យខ្ញុំ! កាលនោះពួកយើងគ្មានមធ្យោបាយទាក់ទងគ្នា ក្រៅតែពីជួបគ្នាដោយផ្ទាល់ឬសរសេរសំបុត្រឱ្យគ្នាឡើយ ... ឯខ្ញុំមិនចូលចិត្តសរសេរសំបុត្រស្នេហាទេ ខ្លាចគេដទៃចាប់យកជាកស្តុតាងបាន ខ្លាចគេសើចចំអក។ ពួកយើងលែងសូវបានជួបមុខគ្នា ... ប៉ុន្តែស្ថានការណ៍មិនបានប្រសើរឡើងឡើយ ... គាត់នៅតែមិនសប្បាយចិត្ត ពេលបានជួបគ្នាម្តងៗចេះតែមានរឿងទាស់សម្តីនឹងគ្នាមិនសូវស្វាង ... គាត់រករឿងខ្ញុំថាខ្ញុំមិនយល់ចិត្តគាត់ ... ឯខ្ញុំរករឿងគាត់ថាគាត់មិនយល់ចិត្តខ្ញុំ ... ពេលបែកគ្នាក៏កើតទុក្ខមុខក្រៀមក្រំតែរៀងខ្លួន! ខ្ញុំគិតថា យី ដល់ហើយតើ ... អញ្ចឹងបានគេថាឱ្យប្រយ័ត្នក្នុងរឿងស្នេហា ពេលស្រលាញ់ក៏ស្រលាញ់ហួស ដល់ទៅពេលត្រូវឈ្លោះ ក៏មានរឿងឈ្លោះមិនចេះចប់!

ល្ងាចមួយ គាត់មកអង្គុយលើកង់រង់ចាំខ្ញុំនៅក្រោមដើមស្វាយតាមទម្លាប់ ប៉ុន្តែគ្រាន់តែខ្ញុំចូលទៅជិតគាត់ក្រោកឈរ ប្រកាសសង្គ្រាមភ្លាម "សិរី ... បើអូនគិតថាពួកយើងគួរនៅបន្តទាក់ទងគ្នាតទៅមុខទៀតពួកយើងត្រូវតែមានភាពប្រាកដប្រជានឹងគ្នា! ... គឺបងត្រូវតែចូលស្តីដណ្តឹងអូនដល់ម៉ាក់ប៉ាជាផ្លូវការ! ពួក

យើងត្រូវតែភ្ជាប់ពាក្យនឹងគ្នាឱ្យបានត្រឹមត្រូវ!"
ខ្ញុំគាន់តាំងអស់ស្មារតី "ភ្ជាប់ពាក្យ? ខ្ញុំទើបតែរៀនដល់ថ្នាក់ទី៩ទេ! បើខ្ញុំភ្ជាប់ពាក្យ គេនឹងសើចឱ្យខ្ញុំស្ងាប់មិនខាន! ពួកយើងបាននិយាយគ្នាច្បាស់ហើយតើ ថាពួកយើងនឹងមិនគិតដល់រឿងភ្ជាប់ពាក្យឬរៀបការទេ លុះត្រាតែអូនបានរៀនចប់ថ្នាក់ឧត្តមសិក្សាសិន!"
"នោះជារឿងដែលយើងនិយាយគ្នាកាលពីមុន!" គាត់ឆ្លើយមកវិញ។
"អញ្ចឹងអ្វីដែលនិយាយគ្នាកាលពីមុន វាគ្មានតម្លៃអ្វីក្នុងពេលបច្ចុប្បន្ននេះទេ?" ខ្ញុំសួរគាត់ភ្លែត។
គាត់មានមុខក្រហម ហាក់ខឹងខ្លាំងណាស់ "បងធ្វើជាសង្ឃឹរលួចលាក់របស់អូនតទៅទៀតមិនបានទេ! បើពួកយើងមិនអាចប្រាកដប្រជានឹងគ្នាទេ ពួកយើងចប់គ្នាត្រឹមហ្នឹងចុះ!"
ខ្ញុំមានអារម្មណ៍ឈឺចាប់ខ្លាំងណាស់ គឺដូចត្រូវកាំបិតដ៏មុតកាត់ផ្តាច់មនោសញ្ចេតនាខ្ញុំយ៉ាងអត់មេត្តា!
ខ្ញុំចង់យំណាស់តែខ្ញុំខំទប់ ... ខ្ញុំឈរត្រង់ខ្លួន ខំនិយាយដោយនឹងនរ "បើបងបានសម្រេចចិត្តបែបហ្នឹងទៅហើយ ... បើនោះជាអ្វីដែលបងត្រូវការ ... ខ្ញុំគ្មានចិត្តចង់ជំទាស់ប្រាថ្នាបងទេ! តែខ្ញុំសូមបញ្ជាក់រឿងមួយឱ្យបានច្បាស់ គឺខ្ញុំអត់ត្រូវការភ្ជាប់ពាក្យជាមួយនរណា ខ្ញុំអត់ត្រូវការរៀបការនឹងនរណាទេ លុះត្រាតែខ្ញុំរៀនបានបរិញ្ញាមួយសិន!"
គាត់និយាយយ៉ាងខ្លីថា "ស្រេចតែចិត្តអូនចុះ!"
ខ្ញុំតបយ៉ាងព្រងើយវិញ "ស្រេចតែចិត្តបងដូចគ្នា!"
គាត់ញញឹមទាំងទឹកមុខជូរចត់ "បងសង្ឃឹមថាអូននឹងបានសប្បាយចិត្ត!"
"ខ្ញុំក៏គិតថាអញ្ចឹងដែរ!" ខ្ញុំបោះសម្តីទៅគាត់វិញភ្លាម។
មុនពេលបែរខ្លួនចាកចេញគាត់សម្លឹងមុខខ្ញុំ "បងសូមជូនពរឱ្យអូនមានជោគជ័យក្នុងការសិក្សាតាមប្រាថ្នា! បងសង្ឃឹមថាអូនបានជួបនឹងបុរសល្អជាស្វាមី! បងសង្ឃឹមថាអូនមានតែក្តីរីករាយ សូមកុំឱ្យអូនជួបប្រទះនឹងរឿងស្នេហ៍ខកខុសបំណងឱ្យសោះ! លាហើយ!" ពោលចប់គាត់ទាញកង់បណ្តើរចាកចេញទៅ។
ខ្ញុំឈរសម្លឹងមើលគាត់ចាកចេញពីខ្ញុំ ... ខ្ញុំចង់យំ តែខ្ញុំខំប្រឹងទប់ទឹកភ្នែកកុំឱ្យស្រក់ហូរចេញមកបាន!

ដួងចិត្តខ្ទេចខ្ទាំ ... ខ្ញុំឈឺចិត្តណាស់! មិនគួរអីខ្ញុំមកជួបប្រទះស្នេហាបាក់បែករបៀបនេះ ... ខ្ញុំធ្លាប់គិតថាខ្ញុំជាមនុស្សម៉ត់ចត់ពិសេសខុសពីនារីទូទៅ មិនសូវចូលចិត្តធ្វើអ្វីឱ្យខុសបំណងទេ! តែរឿងចៀសណាស់បែរជាជួបណាស់ទៅវិញ! ខ្ញុំគិតថាចប់ហើយស្នេហា! តែខ្ញុំនៅនឹកដល់គាត់ជារឿយៗ ... ខ្ញុំក៏ខំបំភ្លេចគាត់យ៉ាងអស់ពីសមត្ថភាព! គឺរាល់ពេលដែលខ្ញុំនឹកដល់គាត់ ខ្ញុំបានខំពង្រឹងមនោសញ្ចេតនាខ្លួនឱ្យរឹងប៉ឹងប្រឹងរុញគាត់ចេញទៅម្ខាង ដើម្បីកុំឱ្យរូបភាពគាត់មកលងអារម្មណ៍ញាំញីចិត្តខ្ញុំទៀត ... ពេលរដូវរំហើយចូលមកដល់ ពេលយល់ផ្កាអង្កាញ់ពណ៌លឿងរីកស្គុះស្គាយនៅតាមដងផ្លូវ ចិត្តខ្ញុំក៏គិតមមៃទៅដល់គ្រាដែលពន្លកស្នេហ៍ទើបដុះដាល ... អនុស្សាវរីយ៍ផ្អែមល្ហែមរំកើបរីករាយក៏ពុះកញ្ជ្រោលពោលពាលមកលាយឡំនឹងរឿប្បយោគទុក្ខ ... ធ្វើឱ្យបេះដូងខ្ញុំឈឺចុកចាប់ស្ទើរតែរបេះដាច់ពីទ្រូង ... តែខ្ញុំធ្លាប់ជាមនុស្សមានះ

និងដឿជាក់លើខ្លួនឯង ខ្ញុំមិនខ្ចីប្រលែងលេងនឹងស្រមោលអនុស្សាវរីយ៍ មិនបណ្តោយឱ្យការឈឺចាប់ចូលមកយាយីខ្ញុំបានតាមចិត្តឡើយ! ខ្ញុំខំរកសៀវភៅផ្សេងៗមកអាន ខ្ញុំខំរៀនអត់ទំនេរ! ខ្ញុំនៅតែជាប់លេខជាសិស្សនាំមុខគេក្នុងថ្នាក់ដដែល!
ខ្ញុំដឹងច្បាស់ក្នុងចិត្តថា ខ្ញុំមុខតែលែងអាចស្រលាញ់អ្នកណាដូចដែលខ្ញុំធ្លាប់ស្រលាញ់គាត់ទៀតហើយ! តែខ្ញុំក៏បានតាំងចិត្តថាមិនបណ្តោយឱ្យអ្នកណាមកបង្កការឈឺចាប់ឱ្យខ្ញុំបែបនេះទៀតជាដាច់ខាត!

ខ្ញុំបានបញ្ចប់ថ្នាក់ទី១០ និងប្រលងជាប់សញ្ញាប័ត្រកំរិតសិក្សាទី២ជាស្តាពរ ... មាតាបិតានិងញាតិកាចង់ឱ្យខ្ញុំរៀនធ្វើជាវេជ្ជបណ្ឌិត ដើម្បីបន្តពូជពង្សខាងពេទ្យ ... តែខ្ញុំអត់មានចំណូលចិត្តធ្វើពេទ្យសោះ ព្រោះខ្ញុំអត់ចូលចិត្តឃើញឈាម ... ជាពិសេសខ្ញុំស្អប់ក្លិននិងខ្ពើមសភាពនៅក្នុងមន្ទីរពេទ្យអ្វីម៉្លេះ ... បើបែបហ្នឹងតើឱ្យខ្ញុំទៅធ្វើពេទ្យម្តេចបាន? ខ្ញុំក៏ដាក់ពាក្យប្រលងខាងអក្សរសាស្ត្រខ្មែរវិញ ... ទោះជាមានអ្នកខ្វះសើចឱ្យខ្ញុំថា "យី មុខអញ្ចឹងចង់ធ្វើគ្រូបង្រៀន?" ក៏ខ្ញុំមិនខ្ចីឈឺក្បាល។
ប៉ុន្តែ ហេតុតែអកុសល ... ខ្ញុំប្រលងចូលសាកលវិទ្យាល័យធ្លាក់ស្នោល! ... ខ្ញុំខ្មាសគេអ្វីម៉្លេះទេ! ខ្ញុំគេងយំអស់រាប់ខែ ... មោទនភាពនិងអំនួតដែលខ្ញុំធ្លាប់មានទាំងប៉ុន្មាន បានបាក់ស្រុតដល់កម្រិតទាបបំផុត! ខ្ញុំចេះតែគិតថាលោកនេះគ្មានយុត្តិធម៌សោះ ... បើទោះជាខំរៀនដល់ឆ្លួត ក៏ប្រហែលជាមិនឈ្នះវាសនាដែលចារមកថាមិនត្រូវបានសមបំណងដែរមើលទៅ?
ខ្ញុំមានងារជាមនុស្សក្បាលរឹង! រឿងអីទើបទទួលបរាជ័យប៉ុណ្ណឹងខ្ញុំព្រមចាញ់? មិនឱ្យខ្ញុំរៀនខាងអក្សរសាស្ត្រខ្មែរហ្អេស? ខ្ញុំទៅរៀនភាសាអង់គ្លេសដើម្បីជាការសងសឹកក៏បាន! ... ខ្ញុំក៏ទៅចុះឈ្មោះចូលរៀនភាសាអង់គ្លេសក្រៅម៉ោងធ្វើការនៅសាកលវិទ្យាល័យភ្នំពេញ គឺសាលាដែលមិនព្រមទទួលខ្ញុំជានិស្សិតស្របច្បាប់នោះឯង។ ខ្ញុំរៀនអង់គ្លេសពេលល្ងាចៗ ពីម៉ោង៥ដល់ម៉ោង៦ ... មិនបានប៉ុន្មានខ្ញុំក៏មានមិត្តភក្តិថ្មីៗ ... មានអ្នកកោតសរសើរពីសំលេងក្នុងការនិយាយ និងចំណេះខាងភាសាអង់គ្លេសរបស់ខ្ញុំជាហែរៗ (ព្រោះកាលនោះ នៅភ្នំពេញមិនសូវសម្បូរអ្នកចេះនិយាយភាសាអង់គ្លេសពិរោះទេ ... អញ្ចឹងសុំអួតបន្តិចចុះ ហេសហេស ...) សូម្បីតែលោកគ្រូក៏និយាយពិរោះចាញ់ខ្ញុំដែរ ... យូរៗទៅគាត់ខ្ចីលទាំងយួរម៉ាស៊ីនចាក់សំលេង (cassette player) មកតាមដល់ថ្នាក់ គាត់ចាប់ឱ្យខ្ញុំអានអត្ថបទផ្សេងៗឱ្យសិស្សឯទៀតស្តាប់ ... នេះបានថាយ៉ាប់ ... ខ្ញុំខំទារឱ្យគាត់បញ្ចុះតម្លៃសិក្សាឱ្យខ្ញុំ តែគាត់មិនព្រម ... តែរឿងបង់លុយនេះមិនសំខាន់ទេ ... ព្រោះខ្ញុំបានស្តារកេរ្តិ៍ឈ្មោះនិងអំនួតមកវិញហើយ ... មិនអន់ឯណា!

ល្ងាចមួយ មិនដឹងខ្យល់អ្វីបក់មកពីខាងណា ស្រាប់តែពេលដើរចេញពីក្នុងថ្នាក់ ខ្ញុំឃើញគាត់ឈរផ្អែកបង្គាន់ដៃនៃរបៀងសាលា នៅពីមុខខ្ញុំឱ្យជ្រដោរ! ខ្ញុំភ្ញាក់ ក៏ឈប់ហើយឈរមើលមុខគាត់ (ប្រហែលជាខ្ញុំបានទាំងធ្វើក្អែកស្វឹងផងមើលទៅ)។ គាត់ញញឹមដាក់ខ្ញុំយ៉ាងស្រពោន ... ខ្ញុំខំញញឹមដាក់គាត់វិញទាំងមានអារម្មណ៍ថាខ្មាសផងអៀនផង ...។

គាត់សួរសុខទុក្ខខ្ញុំ ខ្ញុំក៏ប្រាប់គាត់ថាខ្ញុំបានសុខកាយសប្បាយចិត្តដូចតែធម្មតា! គាត់ស្រដីតិចៗថា គាត់ចូលរួមសោកស្តាយជាមួយខ្ញុំ ដែលខ្ញុំប្រលងចូលសាកលវិទ្យាល័យក្នុងឆ្នាំហ្នឹងមិនជាប់ តែគាត់បន្ថែមថាគាត់មានការជឿជាក់លើខ្ញុំថាខ្ញុំនឹងមិនបោះបង់ក្តីព្យាយាម ... គាត់ថាខ្ញុំមុខតែបានទទួលបរិញ្ញានៅថ្ងៃណាមួយខាងមុខនេះមិនខាន! ខ្ញុំពោលអរគុណគាត់យ៉ាងគួរសមវិញ ទាំងចិត្តភ្ញាក់ផ្អើលនិងខ្លាញ់ ... ហេតុអីគាត់ដឹងពីបរាជ័យរបស់ខ្ញុំច្បាស់ម្ល៉េះ? ឬមួយរយៈពេលបែកគ្នាកន្លងមកនេះ គាត់បានតាមដានខ្ញុំរហូត? ចាប់តាំងពីល្ងាចនោះមក គាត់ក៏បានធ្វើជាអង្គរក្សជិះកង់បណ្តើរខ្ញុំពីសាលាទៅផ្ទះជាថ្មើរវិញ។ ប៉ុន្តែអារម្មណ៍ខ្ញុំចំពោះគាត់បានប្រែប្រួលអស់ទៅហើយ ... កាលពីមុន ពេលបាននៅក្បែរគាត់របៀបនេះ ចិត្តខ្ញុំធ្លាប់តែរំភើបកក់ក្តៅ បេះដូងខ្ញុំធ្លាប់តែលោតញាប់ត្រលប់ត្រលិន ... ម្តេចឥឡូវចិត្តខ្ញុំគ្មានកក្រើករញ្ជួយអ្វីបន្តិច? ម្តេចបេះដូងខ្ញុំលោតយ៉ាងធម្មតា? ហេតុអីគាត់ក៏ដូចជាពួកបុរសនានាដែលខ្ញុំធ្លាប់គិតថាខំចេញមុខចេញមាត់មកយកចិត្តខ្ញុំព្រោះតែចង់ចំណេញពីខ្ញុំ? តើលក្ខណៈពិសេសរបស់គាត់កាលពីមុនបាត់ទៅណាអស់ហើយ? ខ្ញុំខំដណ្តឹងសួរខ្លួនឯង ថាតើស្នេហារបស់ខ្ញុំចំពោះគាត់បានស្លាប់សាបសូន្យរលីងឬអ្វី? ប្រមាណជាបីខែក្រោយមក គាត់បានពោលស្នើសុំមកខ្ញុំថាគាត់មានការណ៍ចង់និយាយនឹងខ្ញុំជាពិសេស ... ពួកយើងក៏អូសទោចក្រយានផងខ្លួនចុះទៅកាន់មាត់ស្រះខាងមុខអាគារធំរបស់សាកលវិទ្យាល័យភ្នំពេញ! គាត់និយាយសុំទោសខ្ញុំ ដែលថ្ងៃនោះគាត់បានផ្តាច់ចំណងស្នេហ៍រវាងយើងទាំងទ្វេ ... គាត់ស្រដីថា គាត់នៅតែស្រលាញ់ខ្ញុំ ថាគាត់មិនដែលភ្លេចខ្ញុំមួយវេលាណាទេ ... គាត់ថាពាក្យសម្បថរបស់គាត់នឹងនៅតែជាប់ស្ថិតស្ថេរជានិរន្តរ៍ គឺគាត់នឹងមិនស្រលាញ់នារីណា មិនរៀបការនឹងនារីណាទេ ក្រៅតែពីរូបខ្ញុំ។ គាត់បានសុំឱ្យខ្ញុំអភ័យទោសឱ្យគាត់ ... គាត់សុំឱ្យខ្ញុំផ្តល់ឱកាសឱ្យពួកយើងបានចាប់ផ្តើមស្នេហ៍ជាថ្មី។

ខ្ញុំសម្លឹងមុខគាត់អស់ពេលជាយូរ ... ខ្ញុំខំសម្លឹងមើលកែវភ្នែកអង្វរកររបស់គាត់ ... ប៉ុន្តែបេះដូងខ្ញុំបែរជានៅតែសំងំស្ងៀម មិនព្រមកម្រើកឬក្រោកមកទទួលយកក្តីស្នេហ៍ពីគាត់ជាថ្មី ... ខ្ញុំសួរខ្លួនឯងថា តើខ្ញុំគួរផ្តល់ឱកាសឱ្យគាត់ម្តងទៀតឬអ្វី? បេះដូងខ្ញុំនៅស្ងៀម ... តែខួរក្បាលខ្ញុំបានធ្វើយភ្លាមថា "ទេ!" គាត់បានចាកចេញចោលខ្ញុំម្តងនោះ គាត់ធ្វើឱ្យខ្ញុំឈឺចាប់ខ្លាំងណាស់! បើគាត់អាចធ្វើបាបខ្ញុំម្តង គាត់មុខតែអាចធ្វើបាបខ្ញុំជាថ្មីម្តងទៀតមិនខាន! ខ្ញុំបានប្តេជ្ញាហើយ ថាខ្ញុំមិនបណ្តោយឱ្យនរណាមកធ្វើបាបញាំញីចិត្តខ្ញុំទៀតទេ! ខ្ញុំក៏និយាយយ៉ាងរាបសារជាមួយគាត់ថា ខ្ញុំសុំទោសដែលខ្ញុំបានបាត់បង់ចិត្តស្រលាញ់ចំពោះគាត់ដូចដែលខ្ញុំធ្លាប់មានអស់ទៅហើយ ហើយខ្ញុំមិនចង់ជួបគាត់ទៀតទេ ... ខ្ញុំបានថ្លែងអំណរគុណដល់គាត់ ដែលគាត់នៅរក្សាវត្តមានរបស់ខ្ញុំនិងពាក្យសន្យារបស់គាត់ជាប់ក្នុងចិត្ត ... ប៉ុន្តែអ្វីដែលកន្លងទៅហើយ មិនអាចត្រលប់ក្រោយ ... ខ្ញុំសូមផ្តល់ឱកាសពេញទំហឹងឱ្យគាត់ចាប់ផ្តើមក្តីស្នេហ៍ជាថ្មីនឹងស្ត្រីដទៃដែលសក្តិសមនឹងគាត់ជាងខ្ញុំ! ខ្ញុំបានសុំឱ្យគាត់លុបពាក្យសម្បថរបស់គាត់ចំពោះខ្ញុំឱ្យអស់ទៅចុះ ... ខ្ញុំបានប្រាប់គាត់ថាព្រះឬទេវតាមុខតែយល់ពីទុក្ខធុរៈរបស់យើង មុខតែប្រណីផ្តល់ឱកាសឱ្យយើងអាចចាប់ផ្តើមក្តីស្រលាញ់ម្តងទៀតជាមួយអ្នកថ្មី។ គាត់ងក់ក្បាល ហើយថាគាត់គោរពការសម្រេចចិត្តរបស់ខ្ញុំ។ គាត់បានសុំជូនខ្ញុំទៅផ្ទះមួយគ្រាជាចុងក្រោយ ... ខ្ញុំក៏មិនជំទាស់ ... ពួកយើងជិះកង់ទន្ទឹមគ្នាយ៉ាងស្ងៀមស្ងាត់ ...

មកដល់មុខផ្ទះខ្ញុំ ពួកយើងឈរសម្លឹងមុខគ្នាដោយស្រងូតស្រងាត់ ... ខ្ញុំឃើញកែវភ្នែកគាត់ជន់ជោរដោយជលនេត្រ គាត់និយាយខ្សឹបៗថា "បងសូមជូនពរអូនឱ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ ... បងគ្រាន់តែសង្ឃឹមថាអូននឹងនឹកដល់បងម្តងម្កាល ... នៅពេលបងស្លាប់ បងសង្ឃឹមថាអូននឹងទៅចូលរួមបុណ្យសពបង និងដាក់ផ្កាស្រស់មួយទង់ទៅលើទ្រូងបងមុនពេលគេបូជារូបបង ... " គាត់បែមុខចេញពីខ្ញុំ ... គាត់ចាប់ទាញកង់មកជិះចេញទៅ ... ខ្ញុំឈរសម្លឹងមើលគាត់ពីក្រោយ ... ខ្ញុំតាមសម្លឹងមើលគាត់លុះត្រាតែស្រមោលគាត់កប់បាត់ក្នុងផង់ធូលីនិងស្បែអន្ធការ ... ខ្ញុំលែងបានឃើញមុខគាត់ជារៀងរហូត ...។

ខ្ញុំក៏បានចូលរៀនយកបរិញ្ញានៅសាកលវិទ្យាល័យដូចបំណង ដោយសិក្សាយកឯកទេសខាងបង្រៀនភាសាអង់គ្លេស ... ខ្ញុំនៅតែសេពគប់មិត្តជាមួយនឹងពួកបុរសៗបានល្អជាងជាមួយពួកនារីៗ ... ប៉ុន្តែខ្ញុំបានសាងកំពែងក្នុងបេះដូងជាច្រើនជាន់ ការពារមិនឱ្យបុរសណាជ្រៀតចូលជ្រៅដល់ក្នុងចិត្តខ្ញុំបានឡើយ ... ឱ្យតែដឹងថាមានន័យកំលោះណា ចង់បង្កបញ្ហានឹងខ្ញុំដោយខំសម្តែងឫកពារលើសពីមិត្តធម្មតា ខ្ញុំនឹងរកឧបាយបង្កើតគម្លាតរវាងយើងទាំងពីរភ្លាម ហើយរកវិធីកំចាត់គេចេញពីវង្វង់មិត្តភាពរបស់ខ្ញុំដោយមិនចាំបាច់ទីមទាមច្រើន ដោយមិនចាំបាច់គិតថាគេនោះល្អឬអាក្រក់យ៉ាងណាទេ! ចិត្តខ្ញុំគឺជារបស់ខ្ញុំតើមែនទេ? គ្រាន់តែខ្ញុំមិនអាចស្រលាញ់ តើខុសអ្វីដែរ? ហើយបើបានជាមិនអាចស្រលាញ់ ខ្ញុំខំជួយដោះលែងគេឱ្យមានសេរីភាព ឱ្យគេបានចេញជាប់ស្រលះពីខ្ញុំ គឺជាគុណបំណាច់ធំណាស់ តើមែនដែរទេ? ប៉ុន្តែពួកប្រុសៗមិនបាននឹកឃើញអរគុណខ្ញុំអញ្ចឹងអី ... បែរជាមានអ្នកលួចសរសេរអក្សរចោលលើក្បាំងម៉ូតូរបស់ខ្ញុំថា "សិរីជានារីអត់បេះដូង!" ខ្ញុំឃើញអក្សរនិងស្គាល់ដល់ម្ចាស់យ៉ាងច្បាស់តែខ្ញុំមិនមាត់មួយម៉ាត់ ខ្ញុំបានទៅរកទិញរូបតូកុនថៃពីរនាក់ឈរឱបគ្នា យកមកបិទលើសំណេរនោះឱ្យព្រងើយ ... មានអ្នកខ្វះឈឺចិត្តជំនួសមិត្តកក្តិ ហ៊ានចេញមុខមករករឿងនិងដាក់បណ្តាសាខ្ញុំថា "មនុស្សចិត្តអាក្រក់! ធ្វើបាបបងធំខ្ញុំឱ្យខូចចិត្ត! ចាំមើល ដាក់ទំនាយឱ្យថ្ងៃក្រោយបានប្តីចិត្តអាក្រក់កុំខាន!"

នៅពេលខ្ញុំចូលដល់ឆ្នាំចុងបញ្ចប់នៃការសិក្សាបរិញ្ញាត្រី (ឆ្នាំទី៤) ស្រាប់តែមានបុរសម្នាក់ក្លាហានខុសគេហ៊ានយកសំបុត្រសារភាពស្នេហ៍និងអត្ថបទរឿងខ្លីដែលគេតាក់តែងឡើងពីអនុស្សាវរីយ៍កាលខ្ញុំនៅរៀនឆ្នាំទីបី មកប្រគល់ឱ្យដល់ដៃខ្ញុំនៅផ្ទះខ្ញុំតែម្តង។ ខ្ញុំធ្លាប់គិតថាបេះដូងខ្ញុំបានស្លាប់ហើយ ខ្ញុំមិនអាចស្រលាញ់បុរសណាបានទៀតឡើយ ... ប៉ុន្តែក្រោយពេលអានរឿងនិទានដ៏ខ្លីនោះចប់ ដើមទ្រូងខ្ញុំចាប់ផ្តើមញ័រចំប្រប់ ... ខ្ញុំរកកល់ស្រក់ទឹកភ្នែក ... ខ្ញុំក៏ចូលចិត្តគេនោះដែរ ប៉ុន្តែតើខ្ញុំអាចផ្តល់ក្តីស្រលាញ់ឱ្យគេវិញបានទេ? នេះជាសំណួរដែលខ្ញុំមិនដឹងចម្លើយ! ខ្ញុំក៏ប្រាប់គេតាមត្រង់ ថាខ្ញុំមិនចង់បដិសេធគេទេ តែខ្ញុំក៏មិនទាន់ចង់រៀបការភ្លាមៗដែរ ខ្ញុំចង់រៀនយកបរិញ្ញាទោ (ម៉ាស្ទ័រ) ឱ្យបានសិន។ ខ្ញុំក៏បានប្រាប់គេយ៉ាងខ្លីផងដែរ ថាខ្ញុំធ្លាប់មានស្នេហាម្តងកាលពីមុន ហើយបេះដូងខ្ញុំនៅរងរបួសយ៉ាងខ្លាំណានៅឡើយ ... បើគេព្រមទុកឱកាសឱ្យខ្ញុំសាកល្បងកសាងក្តីស្នេហ៍ជាថ្មី នោះខ្ញុំនឹងសាកល្បងផ្តល់ឱកាសឱ្យគេនិងឱ្យខ្លួនឯង!

គេក៏បានសារភាពប្រាប់ខ្ញុំថា រូបខ្ញុំក៏មិនមែនជាស្នេហ៍ដំបូងរបស់គេដែរ គេយល់ព្រមប្រើពេលវេលាសាកល្បងជាមួយខ្ញុំ ... ក្រោយពេលខ្ញុំបានទទួលកំណាព្យស្នេហាពីគេម្តងជាពីរដង ខ្ញុំក៏ដឹងថាការសាកល្បងមានជោគជ័យ ព្រោះខ្ញុំបានទទួលក្តីរំភើបរីករាយជាថ្មី ... ខ្ញុំដឹងខ្លួនថាខ្ញុំធ្លាក់ក្នុងអន្ទង់ស្នេហ៍ទៀតហើយ ... ថ្វីបើអារម្មណ៍មិនដូចគ្នានឹងស្នេហ៍គ្រាដំបូង ... តែវាក៏មានសភាពអណ្តែតអណ្តូង មានមនោសញ្ចេតនាផ្អែមល្ហែមមួយបែបផ្សេង ... ទំនងជាមានសភាពនឹងនរនិងស្រគត់ស្រគំជាងពីមុន។

ពួកយើងចំណាយវេលាអស់ប្រាំឆ្នាំដើម្បីស្ទាបស្ទង់ចិត្តគ្នា ... បានឆ្លងកាត់សភាពម្តងត្រជាក់ម្តងក្តៅ ម្តងក់ម្តងជ្រៅនៃអារម្មណ៍របស់យើងជាហូរហែរ ... លុះត្រាតែពួកយើងបានច្បាស់ក្នុងចិត្តថាអាចរួមរស់ជាមួយគ្នាបានហើយ ទើបពួកយើងរៀបការ។ ពួកយើងបានកូនស្រីស្រស់ស្អាតពីររូបជាចំណងដៃ ... ក្រោយមក ពួកយើងក៏ចាកចេញពីស្រុកខ្មែរមកនៅប្រទេសអូស្ត្រាលី។

ខ្ញុំសូមសារភាពថា យូរៗម្តងខ្ញុំបានយល់សប្តិឃើញបុរសទីមួយដែលខ្ញុំធ្លាប់ស្រលាញ់ ... ពេលភ្ញាក់ពីសុបិនវិញ ខ្ញុំមិនអាចមិននឹកគិតដល់គាត់ដោយក្តីសង្វេគឡើយ ទោះជាដឹងហើយ ថានោះជាអតីតកាលដែលខ្ញុំមិនគួររំឭក មិនគួរចងចាំ ... ប៉ុន្តែយូរឆ្នាំហើយ ហេតុអីស្រមោលគាត់នៅតែតាមលងចិត្តខ្ញុំ? ខ្ញុំតែងសង្ឃឹមថាគាត់រកឃើញគូស្នេហ៍ដែលសក្តិសមនឹងគាត់ កសាងជីវិតគ្រួសារដោយក្តីសុខដុមរមនា។

ប្រមាណជាពីរឆ្នាំមុន ខ្ញុំបានជួបមិត្តម្នាក់ដោយចៃដន្យ ... គេនោះគឺជាម្ចាស់ផ្ទះដែលបើកក្លឹបគណិតវិទ្យាកាលពីជាង២០ឆ្នាំមុននោះឯង។ កំពុងតែសួរសុខទុក្ខគ្នាជាធម្មតា មិត្តខ្ញុំស្រាប់តែសួរថា តើខ្ញុំមានដឹងថាអ្នកដឹកនាំក្លឹបបានស្លាប់ទៅហើយទេ? ខ្ញុំកាន់តាំងអស់ស្មារតី នឹកអ្វីមិនឃើញក្រៅតែពីក្តីតក់ស្លុតក្នុងចិត្ត! ខ្ញុំនៅស្ងៀមអស់មួយស្របក់ ទើបអាចបន្ទឺសំណួរថា តើគាត់ស្លាប់ពីកាលណា? មិត្តខ្ញុំឆ្លើយដោយព្រងើយថា "ប្រហែលជាពីរ-បីឆ្នាំហើយ!" ... ខ្ញុំក៏សាកសួរអំពីមូលហេតុនៃមរណភាព ... មិត្តខ្ញុំឆ្លើយថា គេឮថាជាជំងឺមហារីក តែមិនដឹងជាជំងឺមហារីកអ្វីឱ្យប្រាកដទេ។

អ្វីដែលចូលមកញាំញីអារម្មណ៍ខ្ញុំ មិនមែនមានត្រឹមតែដំណឹងមរណភាពរបស់គាត់ទេ គឺខ្ញុំបានដឹងផងដែរថាគាត់មិនដែលរៀបការ និងគ្មានគូកំណាន់ស្នេហារហូតដល់ថ្ងៃស្លាប់ ... តើមុនពេលគាត់ផុតដង្ហើម គាត់មាននឹកមកដល់ខ្ញុំ គាត់មានប្រាថ្នាឃើញមុខខ្ញុំមួយគ្រាជាចុងក្រោយទេ? តើគាត់រំពឹងថាខ្ញុំនឹងទៅចូលរួមបុណ្យសពគាត់ និងដាក់ផ្កាស្រស់មួយទងលើទ្រូងគាត់មុនពេលគេបូជាគាត់ដែរទេ? តើពេលគាត់មកសុំឱ្យខ្ញុំផ្តល់ឱកាសម្តងទៀតនាថ្ងៃនោះ គាត់ដឹងខ្លួនថាគាត់មានជំងឺមហារីកហើយឬអ្វី? បើគាត់មិនទាន់មានជំងឺទេ ហើយបើខ្ញុំព្រមផ្តល់ឱកាសឱ្យគាត់ តើគាត់នៅតែកើតជំងឺដល់ស្លាប់ទាំងក្មេងទៀតឬ? បើពួកយើងរៀបការ មានបុត្រធីតាជាមួយគ្នា តើឥឡូវនេះខ្ញុំបានក្លាយជាស្ត្រីមេម៉ាយ ចិញ្ចឹមកូនតែម្នាក់ឯងហើយឬយ៉ាងណា?

ខ្ញុំដឹងថាខ្ញុំគ្មានថ្ងៃដឹងពីចម្ងើយទាំងនោះទេ ... ខ្ញុំគ្រាន់តែសង្ឃឹមថា ទោះជាវិញ្ញាណក្ខ័ន្ធគាត់ទៅដល់ទីណា សូមឱ្យគាត់បានជួបប្រទះនឹងស្នេហានិងក្តីសុខសមតាមបំណងរបស់គាត់ផងចុះ!! ...